# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ១៤៩

ចុះថ្ងៃទី ១៦_០៣_២០០៩

សាលដីកា

លេខ : ៤៣ "ខ"

ចុះថ្ងៃទី ១៦_០៦_២០១០

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

..........

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៦_០៦_២០១០ ដោយមានសមាសភាពដូចខាងក្រោម:

**ក្រុមប្រឹក្សាជំនុំជម្រះ**

- លោក [redacted] ជាប្រធានក្រុមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោកជំទាវ [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា លី ធិរតី

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ: ១៤៩ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩ ដែលមាន:

- **ជនជាប់ចោទឈ្មោះ** [redacted] ម្មេស ភេទស្រី អាយុ ១៣ឆ្នាំ ជាតិខ្មែរ កើតនៅភូមិលេខ [redacted] ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ២២-១១-០៧ ឃុំខ្លួនថ្ងៃទី ២៣-១១-០៧ ក្រៅឃុំថ្ងៃទី ០៣-១២-០៧។

មានលោក [redacted] ចន្ថា ជាមេធាវីការពារជនជាប់ចោទ។

**ជាប់ចោទពីបទ:** មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិលេខ ៩ ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

- **ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ** [redacted] ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ន [redacted]។

- តាមពាក្យបណ្តឹងឧទ្ធរណ៍លេខ ៧៥ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ជាភាគីរដ្ឋប្បវេណី (ម្តាយជនល្មើស) ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤២ "ប" ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តកណ្តាល ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។/.

## ដំណើររឿងមានដូចតទៅ:

តាមពាក្យបណ្ដឹង ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] ថុង បានបញ្ជាក់ថា នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ វេលាម៉ោង ៤ល្ងាច ពេលនោះកូនខ្លួនបានទៅលេងនៅផ្ទះយាយ ម៉េត មានគ្នា ២នាក់ មួយឈ្មោះ [redacted] ដាវីន ភេទស្រី អាយុ ៤ឆ្នាំ ពេលនោះឈ្មោះ **ម្មេស** បានដេញ **ដាវីន** ឱ្យមកផ្ទះ ហើយបបួលកូនខ្លួនទៅក្រោយផ្ទះ ហើយសម្លាប់ចោលដោះយកក្រវិល ៥ហ៊ុន ពេលប្រពន្ធខ្លួនទៅរកនៅក្រោយផ្ទះ ក៏ប្រទះឃើញសាកសពកូនខ្លួនក្នុងថ្លុកអូរក្រោយផ្ទះ។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤២ "ប" ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តកណ្ដាល ដែលបានសម្រេចសេចក្ដីដូចខាងក្រោម:**

១- ឱ្យឈ្មោះ [redacted] **ម្មេស** (សាវតាជាតិនៅក្នុងសំណុំរឿងស្រាប់) បានរួចផុតពីការទទួលរងទណ្ឌកម្មព្រហ្មទណ្ឌ ពីបទចោទរបស់តំណាងអយ្យការត្រង់មាត្រា ៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ប្រព្រឹត្តនៅភូមិលេខ ៩ ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧។

២- បង្គាប់ឱ្យឈ្មោះ [redacted] **ខ្វី** និងឈ្មោះ [redacted] **ញ៉ាញ់** ជាឪពុកម្ដាយជនជាប់ចោទ រួមគ្នាបង់សំណងរដ្ឋប្បវេណី និងជម្ងឺចិត្តសរុបចំនួន ២០.០០០.០០០រៀល (ម្ភៃលានរៀល) ឱ្យទៅឈ្មោះ [redacted] ជាដើមបណ្ដឹងរដ្ឋប្បវេណី ក្រោយពេលសាលក្រមនេះចូលជាស្ថាពរ។

៣- ខ្សែចងសក់ពណ៌សចំនួនមួយ ក្រវិលចំនួនមួយគូម៉ូតពុកបង្គងធ្វើអំពីលោហៈពណ៌លឿង ដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុតាង ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៧ ឱ្យទៅឈ្មោះ [redacted] ថុង គ្រប់គ្រងថែរក្សាជាសម្បត្តិឯកជនវិញ ក្រោយពេលសាលក្រមនេះចូលជាស្ថាពរ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ទុកសិទ្ធិឱ្យប្ដឹងតវ៉ាក្នុងកំណត់ច្បាប់។

- បានឃើញ ពាក្យបណ្ដឹងឧទ្ធរណ៍លេខ ៧៥ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ញ៉ាញ់ ជាភាគីរដ្ឋប្បវេណី (ម្ដាយជនល្មើស) ប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤២ "ប" ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តកណ្ដាល ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

- បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សាសង្ខេបអង្គហេតុរឿង

ប្រធានក្រុមប្រឹក្សាអានចម្លើយជនជាប់ចោទឈ្មោះ [redacted] **ម្មេស** បានឆ្លើយនៅសាលាដំបូងខេត្តកណ្ដាល។

ឈ្មោះ [redacted] **ញ៉ាញ់** ជាម្ដាយជនជាប់ចោទឆ្លើយថា: ខ្លួនប្ដឹងឧទ្ធរណ៍មកនេះព្រោះខ្លួនគ្មានលុយសងទេ។ សំណូមពរខ្លួនសុំមិនសងលុយទេ ព្រោះគ្មានលុយសង។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ **សេក ថុង** ឆ្លើយថា: ពេលកើតហេតុខ្លួនអត់ដឹងទេ ប្រពន្ធខ្លួននៅផ្ទះបានប្រាប់កូនក៏រកមួយរយៈពេលជាង ១ម៉ោង ទើបឃើញ ពេលរកឃើញ ឃើញកូនស្លាប់នៅក្នុងស្រះទឹក។ ខ្លួនឃើញស្នាមជាំនៅលើក និងស្នាម

នៅលើបបូរមាត់របស់កូនខ្លួន។ កូនខ្លួនកើតនៅឆ្នាំ២០០២។ សំណូមពរ សុំតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨២ "ប" ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តកណ្តាល ។

<u>សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ</u>

សូមក្រុមប្រឹក្សាជំនុំជម្រះសាលាឧទ្ធរណ៍សម្រេចតាមច្បាប់ ។

<u>សេចក្តីសន្និដ្ឋានរបស់មេធាវី</u>

តាមការពិតកូនក្តីខ្លួនប្តឹងឧទ្ធរណ៍ត្រង់ចំណុចសំណង ២០លានរៀល ហើយគាត់មិនមានមុខរបរទេ។ ដូចនេះ សូមក្រុមប្រឹក្សាពិចារណាទៅលើបញ្ហាសំណង បើពិនិត្យលើសាលក្រមគឺជនជាប់ចោទរួចពីទណ្ឌកម្ម ហើយរឿងនេះដើមបណ្តឹងរដ្ឋប្បវេណីមិនបានប្តឹងឧទ្ធរណ៍ទេ សូមក្រុមប្រឹក្សាពិចារណាលើសំណង។

- ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយម្តាយរបស់ជនជាប់ចោទ
- ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់ ។

<u>សាលាឧទ្ធរណ៍ភ្នំពេញ យល់ឃើញថា:</u>

១- បណ្តឹងឧទ្ធរណ៍លេខ ៧៥ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ញ៉ាញ់ ជាភាគីរដ្ឋប្បវេណី ( ម្តាយជនល្មើស) ធ្វើឡើងនៅក្នុងកំណត់ច្បាប់ ។

២- ជនល្មើសបានឆ្លើយសារភាពថា កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ ខ្លួនពិតជាបាននាំកុមារីរងគ្រោះយកទៅសម្លាប់ដើម្បីយកក្រវិលរបស់ជនរងគ្រោះមែន ដោយចាប់ទាញសក់ក្បាលជនរងគ្រោះជ្រមុជទៅក្នុងទឹករហូតដល់ស្លាប់ ព្រោះខ្លួនចង់បានក្រវិលដែលកុមារីរងគ្រោះពាក់នោះតាំងពីបានឃើញកុមារីរងគ្រោះពាក់ពីដំបូងម្លេះ។

៣- មានពិរុទ្ធលើជនល្មើស ពីបទ ឃាតកម្មគិតទុកជាមុន ប្រព្រឹត្តនៅភូមិលេខ ៩ ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ បទល្មើសមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ តែដោយជនល្មើសជាអនីតិជន អាយុ ១៣ឆ្នាំ ទើបតុលាការសម្រេចឱ្យរួចពីទណ្ឌកម្ម ប៉ុន្តែឪពុកម្តាយ ឬអាណាព្យាបាលជាភាគីរដ្ឋប្បវេណី ( អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី) ត្រូវទទួលបន្ទុកសំណងរដ្ឋប្បវេណី ។

៤- សាលក្រមព្រហ្មទណ្ឌលេខ ៨២ "ប" ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តកណ្តាល សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ ។

<u>ហេតុដូច្នេះ</u>

<u>វិនិច្ឆ័យសេចក្តី</u>

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៧៥ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៩ របស់ឈ្មោះ [redacted] ញ៉ាញ់ ជាម្តាយជនល្មើស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤២ "ប" ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការពេញទាំងមូល ។

សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខឈ្មោះ [redacted] ញ៉ាញ់ ជាភាគីរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ។

បើកផ្លូវតវ៉ាតាមកំណត់ច្បាប់ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែងជួយសហការអនុវត្តសាលដីកានេះ ឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់៕

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខាៈ | ហត្ថលេខាៈ | ហត្ថលេខាៈ |
| [redacted] | [redacted] [redacted] | [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤
ក្រឡាបញ្ជី

បានឃើញ
ប្រធានសាលាឧទ្ធរណ៍
[redacted]